جمعية خدمة المحتوى الإسلامي باللغات

ضيوف الرحمن
hajjumrh.com

# សេចក្ដីសង្ខេប អំពីសុជីវធម៌ និងក្បួនច្បាប់នៃការទស្សន **កិច្ចម៉ាស្ជិតណាពី**

ភាសាខ្មែរ

خميري



ضيوف الرحمن
hajjumrh.com

شركاء التنفيذ :

دار الإسلام
بيان الإسلام
رواد التراجم
المحتوى الإسلامي

يتاح طباعة هذا الإصدار ونشره بأي وسيلة مع
الالتزام بالإشارة إلى المصدر وعدم التغيير في النص

Tel : +966 50 244 7000
info@islamiccontent.org
Riyadh 13245-2836
www.islamiccontent.org

រាល់ការសរសើរតម្កើងសម្រាប់អល់ឡោះជាម្ចាស់នៃពិភពទាំងអស់ សូមទ្រង់ប្រទានពរជ័យ និងសុខសន្តិភាពពេញលេញដល់ព្យាការីមូហាំម៉ាត់ ព្រមទាំងក្រុមគ្រួសារហើយនិងសហការី(សហាហ្ពាត់)របស់លោកទាំងអស់គ្នា។

**បន្ទាប់មកទៀត៖**

នេះគឺជាសារសង្ខេបអំពីសុជីវធម៌នៃការទស្សនកិច្ចម៉ាស្ជិតណាពី និងច្បាប់បញ្ញត្តិរបស់វាដែលយើងបានព្យាយាមរៀបរាប់អំពីប្រការចម្បងដែលអ្នកធ្វើអុំរ៉ោះចាំបាច់ត្រូវដឹង។

យើងសុំឱ្យអល់ឡោះជាម្ចាស់ប្រទាន់នូវភាពបរិសុទ្ធចំពោះកិច្ចការមួយនេះសម្រាប់ទ្រង់តែមួយគត់និងក្លាយជាប្រយោជន៍ដល់ប្រជាជនម៉ូស្លីមទាំងអស់គ្នា។

គណៈកម្មការនៃអង្គការបម្រើការមាតិកាសាសនាអ៊ីស្លាមជាភាសានានា



ضيوف الرحمن
hajjumrh.com



# សេចក្ដីសង្ខេប
# អំពីសុជីវធម៌ និងក្បួនច្បាប់នៃ
# ការទស្សនកិច្ចម៉ាស្ជិតណាពី





- គប្បីចំពោះការទស្សនកិច្ចម៉ាស្ជិតណាពី ﷺ គ្រប់ពេលវេលាដោយមិនកំណត់ពេលវេលាជាក់លាក់ណាមួយឡើយ។ហើយវាក៏មិនមែនស្ថិតនៅក្នុងប្រការហាជ្ជីនោះដែរ។ហើយអ្នកធ្វើហាជ្ជីប្រុសស្រីក៏មិនចាំបាច់ត្រូវតែទៅទស្សនកិច្ចផ្នូរណាពីមូហាំម៉ាត់ ﷺ និង ប៉ាកៀកឡើយ។

- មិនអនុញ្ញាតឱ្យព្យាយាមធ្វើដំណើរនៅក្នុងគោលបំណងដើម្បីទៅទស្សនកិច្ចផ្នូរណាពីមូហាំម៉ាត់ ﷺ ឡើយ។ព្រោះការព្យាយាមធ្វើដំណើរគឺដើម្បីគោរពសក្ការៈប៉ុណ្ណោះ មិនមែនជាការទស្សនកិច្ចផ្នូរឡើយ។ហើយត្រូវបានអនុញ្ញាតឱ្យព្យាយាមធ្វើដំណើរទៅកាន់ម៉ាស្ជិតចំនួនបីប៉ុណ្ណោះ។ព្យាការី ﷺ លោកបានមានប្រសាសន៍ថា៖

(لَا تُشَدُّ الرِّحَالُ إِلَّا إِلَى ثَلَاثَةِ مَسَاجِدَ: الْمَسْجِدِ الْحَرَامِ، وَمَسْجِدِي هَذَا، وَالْمَسْجِدِ الْأَقْصَى)

“ចូរពួកអ្នកកុំព្យាយាមធ្វើដំណើរ លើកលែងតែទៅកាន់ម៉ាស្ជិតបីប៉ុណ្ណោះ គឺម៉ាស្ជិតអាល់ហារ៉ម(នៅម៉ាក្កះ) ម៉ាស្ជិតណាពី(នៅម៉ាទីណះ) និងម៉ាស្ជិតអាល់អឹកស(នៅក្រុងយេរូសាឡឹម)” (រាយការណ៍ដោយៈពូខរី៖១១៨៩,និងមូស្លីម៖១៣៩៧)ហើយអ្នកដែលនៅឆ្ងាយពីទីក្រុងម៉ាឌីណះគឺមិនអនុញ្ញាតឱ្យព្យាយាមធ្វើដំណើរនៅក្នុងគោលបំណងដើម្បីទៅទស្សនកិច្ចផ្នូរណាពីមូហាំម៉ាត់ ﷺ ឡើយ។តែក្នុងគោលបំណងដើម្បីគោរពសក្ការៈប៉ុណ្ណោះ។ ហើយនៅពេលដែលគេទៅដល់ទីនោះ គឺគេអាចទៅទស្សនកិច្ចផ្នូរណាពី ﷺ និងផ្នូររបស់សហាហ្ពាត់។ ដូច្នេះ ការទស្សនកិច្ចផ្នូរគ្រាន់តែជាផ្នែកមួយនៃការទស្សនកិច្ចទៅកាន់ម៉ាស្ជិតណាពី ﷺ ប៉ុណ្ណោះ។

ضيوف الرحمن
hajjumrh.com

មិនអនុញ្ញាតឱ្យស្ត្រីទៅទស្សនកិច្ចផ្នូរណាពីមូហាំម៉ាត់□ និងផ្នូរអ្នកផ្សេងទៀតឡើយ ព្រោះណាពី ﷺ បានដាក់បណ្តាសាបណ្តាស្ត្រីទាំងឡាយដែលទៅទស្សនកិច្ចផ្នូរ ដោយសារតែពួកនាងអាចធ្វើអ្វីដែលផ្ទុយពីច្បាប់សាសនា ដូចជាការស្រែកយំ ការបង្ហាញរាយកាយមិនសមរម្យ និងការបំពានផ្សេងទៀត។ ប៉ុន្តែស្ត្រីត្រូវបានលើកទឹកចិត្តឱ្យបង្កើនការទូអាបួងសួងនិងសឡាវ៉ាត់ទៅចំពោះរ៉សូលុលឡោះ ﷺ នៅក្នុងម៉ាស្ជិតឬកន្លែងផ្សេងទៀត។ ការទូអាបួងសួងនិងសឡាវ៉ាត់ទៅចំពោះរ៉សូលុលឡោះﷺ ទាំងនេះនឹងទៅដល់គាត់ﷺ ទោះបីជាពួកគេនៅទីណាក៏ដោយ។ ដូចដែលព្យាការី ﷺ មានប្រសាសន៏ថា៖

(لَا تَجْعَلُوا بُيُوتَكُمْ قُبُورًا، وَلَا تَجْعَلُوا قَبْرِى عِيدًا، وَصَلُّوا عَلَيَّ، فَإِنَّ صَلَاتَكُمْ تَبْلُغُنِي حَيْثُ كُنْتُمْ).

(ចូរកុំទុកផ្ទះរបស់អ្នកដូចជាផ្នូរហើយកុំទុកផ្នូររបស់ខ្ញុំដូចជាកន្លែងធ្វើបុណ្យ។ចូរសឡាវ៉ាតមកចំពោះខ្ញុំព្រោះសឡាវ៉ាតរបស់អ្នកទាំងអស់គ្នានឹងមកដល់ខ្ញុំទោះពួកអ្នកនៅទីកន្លែងណាក៏ដោយ)។ហើយរ៉សូលុលឡោះﷺលោកបានមានប្រសាសន៍ថា ៖

«إِنَّ لِلَّهِ مَلَائِكَةً سَيَّاحِينَ فِي الْأَرْضِ، يُبَلِّغُونِي مِنْ أُمَّتِي السَّلَامَ».

(សម្រាប់អល់ឡោះ គឺមានបណ្តាម៉ាឡាអ៊ីកាត់ដែលធ្វើដំណើរជុំវិញផែនដី ហើយពួកគេនាំមកកាន់ខ្ញុំនូវការបួងសួងសុំសន្តិភាពនៃប្រជាជាតិរបស់ខ្ញុំ)។



- នៅពេលដែលគេបានទៅដល់ម៉ាស្ជិត ស៊ូណិតឲ្យគេឈានជើងស្តាំចូលមុន ហើយសូត្រថា៖

(اللَّهُمَّ افْتَحْ لِي أَبْوَابَ رَحْمَتِكَ)

ដូចជាការចូលក្នុងម៉ាស្ជិតផ្សេងដែរ។

- ហើយការចូលក្នុងម៉ាស្ជិតណាពី ﷺ គឺគ្មានការកំណត់សូត្រអ្វីផ្សេងដោយឡែកឡើយ។

- បន្ទាប់មកត្រូវសឡាតតាហៃយ៉ាតុលម៉ាស្ជិតចំនួនពីររ៉ក្អាត់។

- ប្រសិនបើពេលវេលាដែលគេចូលនោះមិនមែនជាពេលដែលគេហាមឃាត់ទេនោះ គឺគេអាចសឡាតស៊ូណាត់បានតាមចំនួនដែលគេចង់ ដោយធ្វើការឱ្យសឡាតរាល់ពីររ៉ក្អាត់ម្តង។ រ៉ស៊ូលុលឡោះ សអវ លោកបានមានប្រសាសន៍ថា៖

«صَلَاةٌ فِي مَسْجِدِي هَذَا خَيْرٌ مِنْ أَلْفِ صَلَاةٍ فِيمَا سِوَاهُ، إِلَّا الْمَسْجِدَ الْحَرَامَ»

“សឡាតនៅក្នុងម៉ាស្ជិតរបស់ខ្ញុំម្តង គឺល្អជាងសឡាតនៅម៉ាស្ជិតដទៃចំនួនមួយពាន់ដង លើកលែងតែម៉ាស្ជិតអាល់ហារ៉ម(នៅម៉ាក្កះ)ប៉ុណ្ណោះ”។ (ពូខរី៖១១៩០ និង មូស្លីម៖១៣៩៤)






ហើយគេគួរតែព្យាយាមដើម្បីបានចូលសឡាតនៅក្នុងរ៉ាវហ្ទោះ(ជាកន្លែងមួយដែលនៅចន្លោះមីមពើរនិងផ្ទះរបស់គាត់ ដែលមានន័យថា សួនឧទ្យាន) ប្រសិនបើមានភាពងាយស្រួល ព្រោះរ៉សូលុលឡោះ សអវ លោកបានមានប្រសាសន៍ថា៖

«مَا بَيْنَ بَيْتِي وَمِنْبَرِى رَوْضَةٌ مِنْ رِيَاضِ الْجَنَّةِ».

**(កន្លែងមួយដែលនៅចន្លោះមីមពើរនិងផ្ទះរបស់ខ្ញុំគឺជាសួនឧទ្យានមួយនៃសួនឧទ្យានឋានសួគ៍)** (ពូខរី៖១១៩៥ និង មូស្លីម៖១៣៩០) ប្រសិនបើមិនមានភាពងាយស្រួលទេនោះគឺគេអាចសឡាតនៅទីកន្លែងណាក៏បាននៅក្នុងម៉ាស្ជិត។ តែនេះគឺសម្រាប់សឡាតដែលមិនមែនជាចាម៉ាអះប៉ុណ្ណោះ។រីឯការសឡាតចាម៉ាអះវិញគឺគេគប្បីទៅសឡាតនៅជួរទីមួយដែលបន្ទាប់ពីអ៊ីម៉ាំ ដោយមានភស្តុតាងបញ្ជាក់អំពីរឿងនេះ។

## ប្រសិនបើគេចង់ទៅទស្សនកិច្ចផ្នូរណាពី ﷺ និងផ្នូររបស់សហាហ្ពាត់ទាំងពីរ(គឺអាពូហ្ពាកើរ និងអ៊ូមើរ)៖




គេត្រូវឈរនៅទិសខាងមុខផ្នូររបស់ព្យាការីប្រកបដោយសុជីវធម៌ មិនត្រូវតម្លើងសំឡេងខ្លាំងៗឡើយ និងត្រូវមានសេចក្តីថ្លៃថ្នូរហើយត្រូវឱ្យសាឡាមទៅចំពោះណាពី ﷺ ដោយពោលថា៖ السَّلَامُ عَلَيْكَ أَيُّهَا النَّبِيُّ وَرَحْمَةُ اللهِ وَبَرَكَاتُهُ ហើយបើសិនជាពោលទៀតថា៖ أَشْهَدُ أَنَّكَ رَسُولُ اللهِ حَقًّا، وَأَنَّكَ قَدْ بَلَّغْتَ الرِّسَالَةَ، وَأَدَّيْتَ الأَمَانَةَ، وَنَصَحْتَ الأُمَّةَ، وَجَاهَدْتَ فِي اللهِ حَقَّ جِهَادِهِ، فَجَزَاكَ اللهُ عَنْ أُمَّتِكَ أَفْضَلَ مَا جَزَى نَبِيًّا عَنْ أُمَّتِهِ គឺគ្មានបញ្ហាឡើយ។

បន្ទាប់មក ត្រូវឈានជើងស្តាំមួយជំហាន ឬពីរជំហាន ដើម្បីឈរនៅមុខផ្នូររបស់អាពូហ្ពាកើរ រ៉ទីយ៉ល់ឡហ៊ូអាន់ហ៊ូ ហើយត្រូវឲ្យសាឡាមទៅកាន់គាត់។

ក្រោយមក ត្រូវឈានជើងស្តាំមួយជំហាន ឬពីរជំហានទៀត ដើម្បីឈរនៅមុខផ្នូររបស់អ៊ូមើរ រ៉ទីយ៉ល់ឡហ៊ូអាន់ហ៊ូ ហើយត្រូវឲ្យសាឡាមទៅកាន់គាត់។ អ៊ីបនូ អ៊ូមើររ៉ទីយ៉ល់ឡហ៊ូអាន់ហ៊ូម៉ានៅពេលដែលគាត់ឲ្យសាឡាមទៅកាន់ណាពី ﷺ និងសហាហ្ពាត់ទាំងពីរ (គឺអាពូហ្ពាកើរ និងអ៊ូមើរ)៖គឺគាត់មិនដែលពោលពាក្យលើសពីពាក្យថា៖(السَّلَامُ عَلَيْكَ يَا رَسُولَ اللهِ، السَّلَامُ عَلَيْكَ يَا أَبَا بَكْرٍ، السَّلَامُ عَلَيْكَ يَا أَبَتَاهْ) ឡើយ។
 បន្ទាប់មក គាត់ក៏ដើរចាកចេញ។

ហើយរីឯអ្វីដែលអ្នកទស្សនកិច្ចធ្វើអំពីការតម្លើងសំឡេងខ្លាំងៗនៅឯផ្នូរណាពី ﷺ និងឈរនៅទីនោះយូរនោះ គឺវាជាប្រការដែលផ្ទុយពីច្បាប់ឥស្លាម។អល់ឡោះមានបន្ទូលថា៖

﴿يَا أَيُّهَا الَّذِينَ آمَنُوا لَا تَرْفَعُوا أَصْوَاتَكُمْ فَوْقَ صَوْتِ النَّبِيِّ وَلَا تَجْهَرُوا لَهُ بِالْقَوْلِ كَجَهْرِ بَعْضِكُمْ لِبَعْضٍ أَنْ تَحْبَطَ أَعْمَالُكُمْ وَأَنْتُمْ لَا تَشْعُرُونَ، إِنَّ الَّذِينَ يَغُضُّونَ أَصْوَاتَهُمْ عِنْدَ رَسُولِ اللَّهِ أُولَٰئِكَ الَّذِينَ امْتَحَنَ اللَّهُ قُلُوبَهُمْ لِلتَّقْوَىٰ لَهُمْ مَغْفِرَةٌ وَأَجْرٌ عَظِيمٌ﴾

(ឱបណ្ដាអ្នកដែលមានជំនឿ!ចូរពួកអ្នកកុំលើកសំឡេងរបស់ពួកអ្នកខ្លាំងជាងសំឡេងរបស់ណាពី ហើយកុំបន្លឺសំឡេងខ្លាំងៗទៅកាន់គាត់ដូចជាការបន្លឺសំឡេងខ្លាំងៗរបស់ពួកអ្នកទៅកាន់គ្នាឱ្យសោះ ក្រែងលោអំពើល្អទាំងឡាយរបស់ពួកអ្នកបាត់បង់ដោយពួកអ្នកមិនដឹងខ្លួន។
ពិតប្រាកដណាស់បណ្ដាអ្នកដែលថ្នមសំឡេងរបស់ពួកគេនៅចំពោះមុខអ្នកនាំសាររបស់អល់ឡោះអ្នកទាំងនោះ ហើយដែលអល់ឡោះបានសាកល្បងនៅក្នុងចិត្តរបស់ពួកគេដើម្បីឱ្យមានការកោតខ្លាច។ពួកគេនឹងទទួលបានការអភ័យទោស និងផលបុណ្យដ៏ធំធេង។

(អាល់ហ៊ូជីរ៉ត៖ ២-៣)។ ព្រោះតែការដែលឈរនៅយូរនៅឯផ្នូរណាពីﷺហើយឱ្យសាឡាមច្រើនដងនោះនឹងបណ្តាលឱ្យមានការកកស្ទះនិងមានជាការតម្លើងសម្លេងនៅឯផ្នូររបស់គាត់ដែលវាជាទង្វើដែលផ្ទុយពីអ្វីដែលអល់ឡោះ បានបង្គាប់ប្រើមកចំពោះអ្នកអ៊ីស្លាមនៅក្នុងអាយ៉ាត់នេះ។ណាពីﷺត្រូវបានគេគោរពទាំងពេលនៅរស់ និងពេលស្លាប់។ ដូច្នេះ ចាំបាច់លើអ្នកមានជំនឿមិនត្រូវធ្វើអ្វីនៅឯកន្លែងផ្នូរដែលផ្ទុយពីសុជីវធម៌នៅក្នុងច្បាប់អ៊ីស្លាមឡើយ។

ក៏ដូចគ្នាដែរអ្វីដែលអ្នកទស្សនកិច្ចនិងអ្នកផ្សេងទៀតធ្វើអំពីការព្យាយាមទូអាដោយលើកដៃទាំងពីរបែរមុខទៅផ្នូរណាពីﷺទាំងនេះគឺផ្ទុយពីអ្នកជំនាន់មុនអំពីសាឡាហ្វ និងអ្នកបន្ទាប់ពីពួកគាត់នៃពួកតាពីអ៊ីនដ៏ល្អប្រសើរដែលវាគឺជាទង្វើពិទអះ(បង្កើតថ្មីនៅក្នុងសាសនាឥស្លាម)។

ក៏ដូចគ្នាដែរ  អ្វីដែលអ្នកទស្សនកិច្ចធ្វើនៅពេលឱ្យសាឡាមទៅកាន់ណាពីﷺដោយការដាក់ដៃស្តាំលើដៃឆ្វេងលើទ្រូងឬក្រោមទ្រូងដូចគ្នាទៅនឹងពេលសឡាតនោះគឺមិនត្រូវបានអនុញ្ញាតឡើយនៅពេលឱ្យសាឡាមទៅកាន់ណាពី ﷺ ព្រោះការធ្វើបែបនេះវាជារូបភាពនៃការឱនលំទោន បន្ទាបខ្លួន និងគោរពសក្ការៈ ដែលវាមិនគប្បីឡើយ  លើកលែងតែសម្រាប់អល់ឡោះ ដូចដែល អ៊ីបនូហាជើរ បានលើកឡើងនៅក្នុងសៀវភៅ الفتح عن العلماء ។

ហើយមិនត្រូវបានអនុញ្ញាតសម្រាប់នរណាម្នាក់ក្នុងការធ្វើការបញ្ជិតខ្លួនទៅចំពោះអល់ឡោះដោយការស្ទាបប៉ះឬតវ៉ាហ្វជុំវិញផ្ទះណាពីឡើយ។ហើយមិនត្រូវទូអាសុំទៅកាន់ណាពីﷺដើម្បីជួយបំពេញតម្រូវការរបស់គេ ឬឱ្យគេបានជាសះស្បើយពីជំងឺ និងផ្សេងៗទៀតនោះឡើយ  ព្រោះការសុំទូអាទាំងនោះ គឺសម្រាប់អល់ឡោះម្នាក់គត់។

ضيوف الرحمن
hajjumrh.com

គេក៏ស៊ូណិតឲ្យអ្នកដែលទៅទស្សនកិច្ចម៉ាទីណះនៅពេលដែលមានវត្តមាននៅទីនោះគម្បីទៅទស្សនកិច្ចម៉ាស្ជិតគូហ្បាកដើម្បីសឡាតទីនោះ លោកបានទៅ ﷺ ផងដែរ ព្រោះរ៉ស៊ូលុលឡោះ ទីនោះដោយថ្មើរជើងនិងដោយយានជំនិះហើយបានសឡាតនៅក្នុងម៉ាស្ជិតនោះពីររ៉ក្អាត់។ អំពីសាហាល ពិន ហានាហ្វ បាននិយាយថា៖ រ៉ បានមានប្រសាសន៍ថា៖ ﷺ ស៊ូលុលឡោះ

(مَـنْ تَطَهَّـرَ فِي بَيْتِهِ، ثُمَّ أَتَى مَسْـجِدَ قُبَاءٍ، فَـصَلَّى فِيهِ صَلَاةً، كَانَ لَهُ كَأَجْرِ عُمْرَةٍ).

“ជនណាដែលបានយកទឹករ៉ូហ្ពុពីផ្ទះរបស់ខ្លួន ហើយបានធ្វើដំណើរទៅម៉ាស្ជិតគូហ្បាក ហើយបានសឡាតនៅក្នុងវា នោះគេទទួលបានផលបុណ្យស្មើនឹងការធ្វើអ៊ុមរ៉ោះ”។



គេប្រើស៊ូណិតឲ្យទៅទស្សនកិច្ចទីបញ្ចុះសពអាល់ហ្គាកៀក នៅម៉ាទីណះនិងផ្នូររបស់អ្នកដែលបានស្លាប់ស្ហាហ៊ីទនិងផ្នូរហាំហ្សះ رضي الله عنه ព្រោះព្យាការី ﷺ លោកធ្លាប់ទៅទស្សនកិច្ចផ្នូរពួកគេនិងបួងសួងសុំទូអាឲ្យពួកគេហើយរ៉សូលុលឡោះ ﷺ បានមានប្រសាសន៍ថា៖

(كُنْتُ نَهَيْتُكُمْ عَنْ زِيَارَةِ الْقُبُورِ، فَزُورُوهَا، فَإِنَّهَا تُذَكِّرُكُمُ الْآخِرَةَ

(ខ្ញុំធ្លាប់បានហាមអ្នកមិនឱ្យទៅទស្សនកិច្ចផ្នូរ ហើយឥឡូវចូរអ្នកទៅទស្សនកិច្ចវាចុះព្រោះវាធ្វើឱ្យអ្នកនឹកដល់ថ្ងៃបរលោក)ហើយការសូត្រនៅពេលដែលទៅទស្សនកិច្ចទីនោះក៏ដូចជាទៅទស្សនកិច្ចផ្នូរដទៃដែរដោយសូត្រថា៖

(السَّلَامُ عَلَيْكُمْ أَهْلَ الدِّيَارِ مِنَ الْمُؤْمِنِينَ وَالْمُسْلِمِينَ، وَإِنَّا إِنْ شَاءَ اللهُ لَلَاحِقُونَ، أَسْأَلُ اللهَ لَنَا وَلَكُمُ الْعَافِيَةَ)[٢]

ជាការពិតណាស់គោលបំណងនៃការទៅទស្សនកិច្ចផ្នូរគឺដើម្បីនឹកដល់ថ្ងៃបរលោកនិងធ្វើល្អទៅកាន់អ្នកដែលស្លាប់ដោយការទូអាបួងសួងសម្រាប់គេនិងធ្វើតាមស៊ុណ្ណះណាពី ﷺ ដែលនេះគឺជាទស្សនកិច្ចដែលស្របតាមច្បាប់នៃសាសនាឥស្លាម។



ضيوف الرحمن
hajjumrh.com

ហើយរីឯការទស្សនកិច្ចដើម្បីធ្វើការទូអាបួងសួងនៅឯផ្នូររបស់ពួកគេ ឬសុំអល់ឡោះតាមរយៈពួកគេ ឬតាមស្ថានភាពរបស់ពួកគេ ឬផ្សេងទៀតនោះ គឺជាប្រការពិទអះដែលត្រូវបានហាមឃាត់និងមិនត្រូវបានអល់ឡោះនិងណាពីﷺបង្គាប់ប្រើនោះឡើយ។ហើយអ្នកសាឡាហ្វជំនាន់មុនក៏មិនបានធ្វើដែរ។រីឯការសុំជំនួយពីពួកគេ ឬសុំឱ្យជាសះស្បើយពីជំងឺវិញនោះ វាជាប្រការស្ហុីរិកធំ។



## អ្នកអានជាទីគោរពខាងក្រោមនេះគឺជាហាទីសដែលប្រឌិតមួយចំនួនក្នុងរឿងនេះដើម្បីឱ្យអ្នកបានស្គាល់វា និងប្រយ័ត្នអំពីវា៖

- ទីមួយ៖ (អ្នកណាដែលមកធ្វើហាជ្ជីហើយមិនបានមកទស្សនកិច្ចខ្ញុំទេនោះមានន័យថា គេមិនអើពើនឹងខ្ញុំឡើយ)។
- ទីមួយ៖ (អ្នកណាដែលមកធ្វើហាជ្ជីហើយមិនបានមកទស្សនកិច្ចខ្ញុំទេនោះមានន័យថា គេមិនអើពើនឹងខ្ញុំឡើយ)។
- ទីបី៖(អ្នកណាដែលមកទស្សនកិច្ចខ្ញុំ និងឪពុករបស់ខ្ញុំនៅឆ្នាំតែមួយនោះខ្ញុំនឹងធានានូវឋានសួគ៌ពីអល់ឡោះជូនគេ)។
- ទីបួន៖ (អ្នកណាដែលមកទស្សនកិច្ចផ្នូររបស់ខ្ញុំ គឺគេនឹងត្រូវទទួលបានការស្ហាហ្វាអាត់(ជួយអន្តរាគម)ពីខ្ញុំ)។

ហាទីសទាំងនេះ និងហាទីសស្រដៀងគ្នាមួយចំនួនទៀត គឺគ្មានការបញ្ជាក់ពីណាពី ﷺ ឡើយ។ អាល់ហាហ្វីស អាល់អាគីលី បាននិយាយថា៖ គ្មានអ្វីដែលត្រឹមត្រូវក្នុងរឿងនេះទេ។អាល់ហាហ្វីសអ៊ិបនូហាជើរអាល់អាសក៏ឡានី បាននិយាយនៅក្នុងគីតាប التلخيص ថា៖ បន្ទាប់ពីបានរៀបរាប់ជាច្រើននៃរីវ៉ាយីតទាំងនេះគឺសាណាត់ទាំងអស់នៃហាទីសនេះគឺខ្សោយ។ ការធ្វើទស្សនកិច្ចម៉ាស្ជិតរបស់ណាពីនៅមុន ឬក្រោយពេលធ្វើហាជ្ជី ឬអ៊ុំរ៉ោះវាមិនមែនជាស៊ុណ្ណះនៃការធ្វើហាជ្ជីឬអ៊ុំរ៉ោះឬធ្វើឲ្យវាទាំងពីរមានភាពពេញលេញនោះឡើយ។ដោយសារតែការទៅទស្សនកិច្ចម៉ាស្ជិតរបស់ណាពីគឺជាប្រការស៊ូណាត់ដាច់ដោយឡែក។ ប្រសិនបើអ្នកធ្វើហាជ្ជី ឬអ៊ុំរ៉ោះមិនបានទៅទស្សនកិច្ចវាទេក៏គ្មានបាបកម្មលើគេឡើយហើយមិនមានទំនាក់ទំនងរវាងការធ្វើហាជ្ជីឬអ៊ុំរ៉ោះនិងការទៅទស្សនកិច្ចម៉ាស្ជិតរបស់ណាពីទេ ព្រោះវាជាសកម្មភាពនៃការគោរពសក្ការៈដាច់ដោយឡែក។ អ្នកណាដែលធ្វើហាជ្ជី ឬអ៊ុំរ៉ោះ មិនមានកាតព្វកិច្ចទៅទស្សនកិច្ចម៉ាស្ជិតរបស់ណាពីឡើយ ហើយដូចគ្នាដែរ អ្នកណាដែលទៅទស្សនកិច្ចម៉ាស្ជិតរបស់ណាពីក៏មិនមានកាតព្វកិច្ចធ្វើហាជ្ជីឬអ៊ុំរ៉ោះដែរ។ហើយប្រសិនបើគេចង់រួមបញ្ចូលការធ្វើហាជ្ជី ឬអ៊ុំរ៉ោះ និងការទស្សនកិច្ចម៉ាស្ជិតរបស់ណាពីក្នុងការធ្វើដំណើរតែមួយនោះ វាក៏មិនមានបញ្ហាអ្វីនោះទេ។

ضيوف الرحمن
hajjumrh.com

# កំហុសឆ្គងនៅពេលទៅទស្សនកិច្ចម៉ាស្ជិតណាពី

- ជូតជញ្ជាំងនិងរនាំងដែកពេលទៅទស្សនកិច្ចផ្នូរណាពី ហើយចងខ្សែ និងរបស់ផ្សេងៗនឹងបង្អួចដើម្បីជាការតាពើររួក(ផ្នូរដើម្បីទទួលពរជ័យ)។

- ហើយពរជ័យ(ហ្គារ៉កាស)គឺជាអ្វីដែលអល់ឡោះនិងណាពី ﷺ បង្គាប់ប្រើ មិនមែនជាទង្វើពិទអះ(បង្កើតថ្មីនៅក្នុងសាសនាឥស្លាម)។
ការទៅកាន់រូងភ្នំអ៊ូហូទនិងរូងភ្នំហេរ៉ានិងរូងភ្នំហ្សួរនៅក្រុងម៉ាក្កះហើយចងក្រណាត់នៅទីនោះនិងទូអាបួងសួងដោយពាក្យដែលអល់ឡោះមិនអនុញ្ញាតហើយទ្រាំនឹងការលំបាកក្នុងការធ្វើដូច្នេះ។

**ទាំងអស់នេះជាទង្វើពិទអ(ការបង្កើតថ្មីនៅក្នុងសាសនា) ដែលគ្មានប្រភពពីច្បាប់ឥស្លាមដែលល្អិតតខ្ជោះនោះឡើយ។**



ضيوف الرحمن
hajjumrh.com

- ទៅទស្សនកិច្ចកន្លែងមួយចំនួនដែលគេអះអាងថាជាកេរដំណែលឬស្លាកស្នាមរបស់ណាពីﷺ ដូចជាកន្លែងសម្រាករបស់សត្វអូដ្ឋ អណ្តូងអាល់ខទិម ឬអណ្តូងអ៊ូស្មាន និងយកដីពីកន្លែងទាំងនេះដើម្បីសុំបារ៉ាកាស (ជាថ្នូរដើម្បីទទួលពរជ័យ)។

- សុំទូអាពីអ្នកស្លាប់នៅពេលទៅទស្សនកិច្ចទីបញ្ចុះសពអាល់ហ្គាកៀកនិងទីបញ្ចុះសពអាសស្ហូហាទើក(ទុក្ករបុគ្គល)អ៊ូហូទហើយបោះលុយនៅទីនោះដើម្បីជាការបញ្ជិតខ្លួនទៅកាន់ពួកគេ និងស្វែងរកការតាពើររួក(ពរជ័យ)ពីក្រុមគ្រួសាររបស់ពួកគេ។

ដែលនេះគឺជាកំហុសឆ្គងដ៏ធ្ងន់ធ្ងរមួយនិងជាទង្វើស្ហ៊ីរិកធំដូចដែលសាសនវិទូឥស្លាមបានរៀបរាប់ប្រាប់និងបានបញ្ជាក់នៅក្នុងគម្ពីរគួរអាន និងស៊ុណ្ណះរបស់ណាពី ﷺ ។ ពីព្រោះកិច្ចគោរពសក្ការៈគឺសម្រាប់អល់ឡោះតែមួយប៉ុណ្ណោះហើយវាមិនត្រូវបានអនុញ្ញាត្តិឱ្យបង្វែរវាទៅកាន់អ្នកដ៏ទៃនោះឡើយ ដូចជាការទូអាបួងសួង ការសំឡះសត្វការស្បថនិងអ្វីៗផ្សេងទៀតដោយផ្អែកលើព្រះបន្ទូលរបស់ទ្រង់៖

﴿وَمَا أُمِرُوا إِلَّا لِيَعْبُدُوا اللَّهَ مُخْلِصِينَ لَهُ الدِّينَ﴾

(ហើយពួកគេមិនត្រូវបានគេបញ្ជាឱ្យធ្វើអ្វីក្រៅពីឱ្យពួកគេគោរពសក្ការៈចំពោះអល់ឡោះដោយចិត្តស្មោះសចំពោះទ្រង់ឡើយ) (អាល់ពៃយីណះ ៖ ៥)

والله أعلم، وصلى الله وسلم على نبينا محمد، وعلى آله وصحبه أجمعين.



# تعرف على الإسلام

## بأكثر من 100 لغة

موسوعة الأحاديث النبوية
HadeethEnc.com

ترجمات متقنة للأحاديث النبوية وشروحها بأكثر من (60) لغة

بيان الإسلام
byenah.com

مواد منتقاة للتعريف بالإسلام وتعليمه بأكثر من (120) لغة

موسوعة القرآن الكريم
QuranEnc.com

ترجمات متقنة لمعاني القرآن الكريم بأكثر من (75) لغة

موسوعات وخدمات إسلامية باللغات
s.islamenc.com

للمزيد من المواقع الإسلامية بلغـــــات العـــــالم

جامع المحتوى الإسلامي باللغات
islamcontent.com

مواد إسلامية متنوعة وشاملة بأكثر من (125) لغة

ضيوف الرحمن
hajjumrh.com

مواد منتقاة للحجــــاج والمعتمرين و الزوار بلغات العالم

جمعية خدمة المحتوى الإسلامي باللغات

ضيوف الرحمن
hajjumrh.com